# ជប៉ុនផ្តល់ទឹកប្រាក់ជាង២សែនដុល្លារ សម្រាប់គម្រោងការ៦នៅកម្ពុជា

រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ជំនួយឥតសំណងទៅលើគម្រោងការអភិវឌ្ឍន៍ចំនួន៦ដែលមានទឹកប្រាក់សរុប២២៦.៣៤២ដុល្លារអាមេរិក សម្រាប់គម្រោងការទ្រង់ទ្រាយតូច «គូសាណូណេ» ។

គម្រោងការទាំង៦នោះ រួមមានគម្រោងការទី១ : ជួយគាំទ្រការសាងសង់អណ្តូងទឹកនៅក្នុងខេត្តឧត្តរមានជ័យ ដែលមានទឹកប្រាក់១៨.០៦៥ដុល្លារអាមេរិក តាមរយៈអង្គការអភិវឌ្ឍន៍បរិស្ថាន និងសហគមន៍ជនបទ(RCEDO) ។ ទឹកប្រាក់នេះនឹងជួយសាងសង់អណ្តូងទឹកយោងដោយដៃចំនួន១០ និងអណ្តូងស្នប់ចំនួន១០ ព្រមទាំងគ្រឿងបន្លាស់ខ្លះទៀតនៅឃុំបុសស្បូវ ស្រុកសំរោង ដើម្បីផ្គត់ផ្គង់ទឹកស្អាតនិងកែលំអស្ថានភាពអនាម័យរបស់ប្រជាជននៅទីនោះ ។

គម្រោងការទី២ គឺមានទឹកប្រាក់៧៣.៣១០ដុល្លារអាមេរិក ជួយដល់មន្ទីរអប់រំយុវជននិងកីឡានៃសាលាក្រុងភ្នំពេញ សម្រាប់គម្រោងការផ្តល់គ្រឿងបរិក្ខារសិក្សាដែលប្រើប្រាស់ម្តងហើយដល់សាលាបឋមសិក្សានៅទីក្រុងភ្នំពេញ ។

គម្រោងទី៣ ផ្តល់ឱ្យការិយាល័យអប់រំយុវជននិងកីឡានៃខណ្ឌចំការមនទីក្រុងភ្នំពេញ សម្រាប់គម្រោងការផ្តល់គ្រឿងបរិក្ខារសិក្សា ដែលប្រើប្រាស់ម្តងហើយ ដល់អនុវិទ្យាល័យនៅក្នុងខណ្ឌចំការមននៃទីក្រុងភ្នំពេញ ដែលមានទឹកប្រាក់៦៤.៤៦៩ដុល្លារអាមេរិក ។

គម្រោងការទី៤ គឺផ្តល់គ្រឿងបរិក្ខារសិក្សាដែលប្រើប្រាស់ម្តងហើយដល់អនុវិទ្យាល័យនិងវិទ្យាល័យនៅក្នុងខណ្ឌដូនពេញ ទីក្រុងភ្នំពេញ ដែលមានទឹកប្រាក់៦៩.៨០៥ដុល្លារអាមេរិក ផ្តល់ឱ្យតាមរយៈការិយាល័យអប់រំយុវជននិងកីឡានៃខណ្ឌដូនពេញរាជធានីភ្នំពេញ ។

ការផ្តល់គ្រឿងបរិក្ខារសិក្សាដល់គម្រោងទាំង៣នេះ មានតុ និងកៅអីជាង៧.៦០០សម្រាប់ សម្រាប់ចែកដល់សាលាបឋមសិក្សាចំនួន១១នៅទីក្រុងភ្នំពេញ និងដល់អនុវិទ្យាល័យនិងវិទ្យាល័យចំនួន៤ ក្នុងខណ្ឌចំការមននិងខណ្ឌដូនពេញ ។ សម្ភារៈនេះត្រូវបានឧបត្ថម្ភពីទីក្រុងមីសាតូ នៃខេត្តជីបា និងទីក្រុងសាប់ប៉ូរ៉ូ នៃខេត្តហុកកៃដូក្នុងប្រទេសជប៉ុន ។ ទឹកប្រាក់នៃគម្រោងការនេះគឺសម្រាប់ការដឹកជញ្ជូនតាមនាវាពីប្រទេសជប៉ុនមកកាន់កម្ពុជា និងការដឹកជញ្ជូនទៅដល់សាលានីមួយៗ ។

គម្រោងការទី៥ គឺផ្តល់ឱ្យអង្គការ Chibaken Lion Club Cambodia Project (CLCP)ដែលមានទឹកប្រាក់២២.៣៧៨ដុល្លារ សម្រាប់សាងសង់អគារសិក្សាមួយខ្នងមាន៥បន្ទប់នៅសាលាបឋមសិក្សាជន្លង់ ក្នុងខេត្តសៀមរាប រួមទាំងគ្រឿងបរិក្ខារសិក្សាចាំបាច់ដូចជា ក្តារខៀន តុ កៅអីគ្រូ និងតុកៅអីសិស្ស នឹងត្រូវផ្តល់ជូនផងដែរដោយគម្រោងការនេះ ដើម្បីជាប្រយោជន៍ដល់សិស្សពេញវ័យសិក្សាប្រហែល៧០០នាក់ ដែលកំពុងរស់នៅក្នុងភូមិចំនួន៤ ក្បែរសាលារៀននេះ។

គម្រោងទី៦ ផ្តល់ឱ្យអង្គការ Tateyama Minami Lion Club ដែលមានទឹកប្រាក់១៨.២១៥ដុល្លារអាមេរិកសម្រាប់សាងសង់អគារសិក្សាមួយខ្នងមាន៥បន្ទប់ នៅសាលាបឋមសិក្សាទួលកោកុះ នៅទីក្រុងភ្នំពេញ ដើម្បីជាប្រយោជន៍ដល់កុមារពេញវ័យសិក្សាប្រហែល៣០០នាក់ ។ គម្រោងការនេះគឺដើម្បីចូលរួមវិភាគទានផងដែរដល់ផែនការតាំងទីលំនៅថ្មីរបស់សាលាក្រុងភ្នំពេញ ។

គម្រោងការផ្តល់ជំនួយទាំងនេះ នឹងត្រូវចុះហត្ថលេខាដោយលោក ហ្គោតារ៉ូ អូហ្គាវ៉ា ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា និងអ្នកតំណាងនៃអង្គការទទួលជំនួយទាំងនេះ នៅថ្ងៃទី២០ខែកក្កដាឆ្នាំ២០០១ វេលាម៉ោង១១ព្រឹកនៅក្នុងបន្ទប់ប្រជុំរបស់ស្ថានទូតជប៉ុន ។

គួរបញ្ជាក់ថា «គូសាណូណេ» បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩២ ដើម្បីជួយដល់ការខិតខំប្រឹងប្រែងអភិវឌ្ឍន៍និងស្តារឡើងវិញនៅតាមជនបទនៃប្រទេសកម្ពុជា ។ រហូតមកដល់ពេលនេះមានទឹកប្រាក់សរុប១០.៥៥១.៤០២ដុល្លារសម្រាប់១៩៣គម្រោងនៅក្នុងប្រទេសកម្ពុជា ។

ភារារិទ្ធ

Rasmei Kampuchea

July 22, 2001